ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានរតនាគារជាតិ

# គោលការណ៍ណែនាំ
# ស្តីពី
# កិច្ចបញ្ជិកាគណនេយ្យនៃសន្និធិ

២០២៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.៥៥៥.......សហវ.ប្រក.ទសបតាន

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពី
# កិច្ចបញ្ជិកាគណនេយ្យនៃសន្និធិ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០០១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការបង្កើតវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៧១ អនក្រ.បក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៥៩ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងថវិកា គណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យអនុវត្តគោលការណ៍ណែនាំ ស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃសន្និធិ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះរដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

ប្រកាសនេះពុំមានវិសាលភាពអនុវត្តចំពោះសហគ្រាសសាធារណៈឡើយ។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សៅរ៍ ១៤ កើត ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ណែនាំ
# ស្តីពី
# កិច្ចបញ្ជិកាគណនេយ្យនៃសន្និធិ

ជាឧបសម្ព័ន្ធនៃប្រកាសលេខ ...៤៧៩........ សហវ.ប្រក ចុះថ្ងៃទី...៣១... ខែ.....ធ្នូ...... ឆ្នាំ២០២៤
ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃសន្និធិ

# មាតិកា


| | | ទំព័រ |
|---|---|---|
| **ជំពូកទី១** | **បទប្បញ្ញត្តិទូទៅ** | **១** |
| ១. | គោលបំណង | ១ |
| ២. | វិសាលភាព | ១ |
| ៣. | និយមន័យ | ២ |
| **ជំពូកទី២** | **ការទទួលស្គាល់និងការវាស់វែងសន្និធិ** | **៣** |
| | **ផ្នែកទី១៖ ការទទួលស្គាល់សន្និធិ** | **៣** |
| ១. | លក្ខខណ្ឌនៃការទទួលស្គាល់សន្និធិជាទ្រព្យសកម្មរយៈពេលខ្លី | ៣ |
| ២. | លក្ខខណ្ឌនៃការទទួលស្គាល់សន្និធិជាចំណាយថ្លៃដើម | ៣ |
| | **ផ្នែកទី២៖ ការវាស់វែងសន្និធិ** | **៣** |
| ១. | ការវាស់វែងសន្និធិ | ៤ |
| ២. | ថ្លៃដើម | ៥ |
| ២.១ | ធាតុនៃថ្លៃដើមសន្និធិ | ៥ |
| ២.២ | ថ្លៃដើមសន្និធិរបស់អ្នកផ្តល់សេវា | ៧ |
| ២.៣ | ថ្លៃដើមផលិតផលកសិកម្មដែលបានប្រមូលកាត់ពីទ្រព្យសកម្មជីវសាស្ត្រ | ៧ |
| ២.៤ | វិធីសាស្ត្រវាស់វែងថ្លៃដើម | ៨ |
| ២.៥ | វិធីសាស្ត្រគណនាថ្លៃដើម | ៨ |
| ២.៦ | តម្លៃសុទ្ធដែលអាចទទួលបាន | ៨ |
| ២.៧ | ការបែកចាយសន្និធិដោយមិនគិតថ្លៃ ឬ គិតថ្លៃតិចតួច | ៩ |
| **ជំពូកទី៣** | **គណនេយ្យកម្មសន្និធិ** | **១០** |
| ១. | លក្ខខណ្ឌនៃការទទួលស្គាល់សន្និធិ | ១០ |
| ២. | លក្ខខណ្ឌនៃការទទួលស្គាល់ជាចំណាយថ្លៃដើម | ១១ |
| **ជំពូកទី៤** | **ការឈប់ទទួលស្គាល់សន្និធិ** | **១៣** |
| ១. | លក្ខខណ្ឌនៃការឈប់ទទួលស្គាល់សន្និធិ | ១៣ |
| ២. | គណនេយ្យកម្មនៃការឈប់ទទួលស្គាល់សន្និធិ | ១៣ |
| **ជំពូកទី៥** | **វិហ្វរដំណើរការនិងការរាយការណ៍សន្និធិ** | **១៥** |
| ១. | ភាគីពាក់ព័ន្ធ | ១៥ |
| ២. | វិហ្វរដំណើរការ | ១៥ |
| ៣. | ឯកសារតម្រូវ | ១៥ |
| ៤. | សមតុល្យដើមគ្រានៃសន្និធិ | ១៦ |
| ៥. | ការរាប់សន្និធិជាក់ស្តែង | ១៦ |
| ៦. | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់កត់ត្រា និងរាយការណ៍សន្និធិ | ១៦ |
| ៧. | ការរាយការណ៍សន្និធិ | ១៧ |

៨. ការដាក់បង្ហាញសន្និធិក្នុងរបាយការណ៍ ១៧

**ឧបសម្ព័ន្ធ៖**

ឧបសម្ព័ន្ធ១ ការផ្ទៀងផ្ទាត់សន្និធិជាមួយនឹងលក្ខខណ្ឌតម្រូវនៃស្តង់ដាគណនេយ្យសាធារណៈកម្ពុជា ១៨
ឧបសម្ព័ន្ធ២ គំរូរបាយការណ៍សន្និធិ ២១
ឧបសម្ព័ន្ធ៣ គំរូរបាយការណ៍សរុបរួមសន្និធិ ២២

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

## ១. គោលបំណង

គោលការណ៍ណែនាំនេះ បានកំណត់អំពីលក្ខខណ្ឌនៃការទទួលស្គាល់ ការវាស់វែង និងផ្តល់នូវការណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃសន្និធិ ឱ្យបានត្រឹមត្រូវ ទៅតាមស្តង់ដាគណនេយ្យសាធារណៈ ដើម្បីឱ្យការរាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវនៃប្រតិបត្តិការហិរញ្ញវត្ថុ(របាយការណ៍លទ្ធផល) និងស្ថានភាពហិរញ្ញវត្ថុ(តារាងតុល្យការ) របស់ស្ថាប័នសាធារណៈ។

គោលការណ៍ណែនាំនេះ ក៏ជាផ្នែកមួយនៃផែនការផ្លាស់ប្តូរប្រព័ន្ធគណនេយ្យសាធារណៈមូលដ្ឋានសាច់ប្រាក់ទៅប្រព័ន្ធគណនេយ្យសាធារណៈមូលដ្ឋានបង្គរ ស្របតាមផែនការសកម្មភាពនៃការងារកែទម្រង់របស់អគ្គនាយកដ្ឋានរតនាគារជាតិ និងយុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា២០២១-២០៣១។

គោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងដោយស្របតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា និងស្តង់ដាគណនេយ្យសាធារណៈអន្តរជាតិលេខ ១២ ស្តីពីសន្និធិ។

## ២. វិសាលភាព

គោលការណ៍ណែនាំនេះ អនុវត្តចំពោះស្ថាប័នសាធារណៈ។ គោលការណ៍ណែនាំនេះ ត្រូវយកទៅអនុវត្តចំពោះលក្ខខណ្ឌនៃការទទួលស្គាល់ និងកិច្ចបញ្ជិកាគណនេយ្យនៃសន្និធិ ទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលសម្រាប់ស្ថាប័នសាធារណៈដែលពាក់ព័ន្ធ លើកលែងតែ៖

ក. ការងារកំពុងដំណើរការដែលកើតឡើងក្រោមកិច្ចសន្យាសាងសង់ រួមបញ្ចូលទាំងកិច្ចសន្យាសេវាពាក់ព័ន្ធដោយផ្ទាល់

ខ. ឧបករណ៍ហិរញ្ញវត្ថុ

គ. ទ្រព្យសកម្មជីវសាស្ត្រដែលពាក់ព័ន្ធនឹងកសិកម្ម និងផលិតផលកសិកម្ម នៅពេលច្រូតកាត់ប្រមូលផល

ឃ.ការងារកំពុងដំណើរការនៃសេវាដែលត្រូវផ្តល់ ដែលគ្មានការតបស្នង ឬការតបស្នងធម្មតាតិចតួចដោយផ្ទាល់ពីអ្នកទទួលសេវា។

គោលការណ៍ណែនាំនេះ មិនអនុវត្តចំពោះការវាស់វែងសន្និធិដែលបានរក្សាទុកដោយ៖

(១). អ្នកផលិត ផលិតផលកសិកម្មនិងព្រៃឈើ, ផលិតផលកសិកម្មបន្ទាប់ពីច្រូតកាត់ប្រមូលផល, និងធនធានព្រមទាំងរ៉ែ និងផលិតផលរ៉ែក្នុងវិសាលភាពដែលផលិតផលទាំងនេះត្រូវបានវាស់វែងតាមតម្លៃសុទ្ធដែលអាចទទួលបាន ដោយអនុលោមតាមឧត្តមានុវត្តន៍នៅក្នុងវិស័យទាំងនោះ។ នៅពេលសន្និធិទាំងនេះត្រូវបានវាស់វែង តាមតម្លៃសុទ្ធដែលអាចទទួលបាន ការប្រែប្រួលតម្លៃនោះត្រូវទទួលស្គាល់ក្នុងរបាយការណ៍ជា អតិរេក ឬ ឱនភាព នៅក្នុងការិយបរិច្ឆេទដែលការប្រែប្រួលទាំងនោះកើតឡើង និង

(២). អ្នកជួញដូរទំនិញឈ្មួញកណ្តាលដែលវាស់វែងសន្និធិរបស់ពួកគេ តាមតម្លៃសមស្រប ដកថ្លៃដើមលក់។ នៅពេលសន្និធិទាំងនេះត្រូវបានវាស់វែងតាមតម្លៃសមស្របដកថ្លៃដើមលក់ ការប្រែប្រួលតម្លៃសមស្រប ដកថ្លៃដើមលក់ត្រូវទទួលស្គាល់នៅក្នុងគណនីអតិរេក ឬ ឱនភាពនៅក្នុងការិយបរិច្ឆេទនៃការប្រែប្រួលនោះ។

## ៣. និយមន័យ

ពាក្យ ឬ វាក្យសព្ទដែលប្រើប្រាស់នៅក្នុងគោលការណ៍ណែនាំនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

**ថ្លៃដើមជំនួសបច្ចុប្បន្ន** (Current Replacement Cost) គឺជាតម្លៃប៉ាន់ស្មាននៃទ្រព្យនៅការិយបរិច្ឆេទរាយការណ៍។

**តម្លៃសុទ្ធដែលអាចទទួលបាន** គឺជាតម្លៃលក់ប៉ាន់ស្មានក្នុងដំណើរកិច្ចប្រតិបត្តិការធម្មតា ដកថ្លៃដើមបញ្ចប់ប៉ាន់ស្មាន និងថ្លៃដើមប៉ាន់ស្មាននានាដែលចាំបាច់ដើម្បីលក់ ដោះដូរ ឬ ចែកចាយ។

**ថ្លៃដើម** គឺជាចំនួននៃសាច់ប្រាក់ ឬ សាច់ប្រាក់សមមូល ដែលត្រូវបានទូទាត់ ឬ តម្លៃសមស្របនៃតម្លៃតបស្នងដែលត្រូវផ្តល់ ដើម្បីទិញ ឬ ទទួលបានទ្រព្យសកម្ម នៅពេលសាងសង់ ឬ ទទួលបានទ្រព្យសកម្មទាំងនោះ។

**ទ្រព្យសកម្ម** គឺជាធនធានដែលត្រូវបានគ្រប់គ្រង ដោយសារលទ្ធផលនៃព្រឹត្តិការណ៍ក្នុងអតីតកាល ដោយរំពឹងថានឹងផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលនឹងហូរចូលស្ថាប័នសាធារណៈ។

**ប្រតិបត្តិការមិនដោះដូរ** សំដៅដល់ប្រតិបត្តិការក្រៅពីប្រតិបត្តិការដោះដូរ។ ក្នុងប្រតិបត្តិការមិនដោះដូរ ស្ថាប័នសាធារណៈមួយអាចទទួលបានតម្លៃពីស្ថាប័នមួយផ្សេងទៀត ដោយមិនផ្តល់តម្លៃប្រហាក់ប្រហែលដោយផ្ទាល់ណាមួយជាថ្នូរក្នុងការដោះដូរ ឬ ផ្តល់តម្លៃទៅឱ្យស្ថាប័នមួយផ្សេងទៀត ដែលមិនទទួលបានតម្លៃប្រហាក់ប្រហែលដោយផ្ទាល់ណាមួយជាថ្នូរក្នុងការដោះដូរ។ ឧទាហរណ៍ ក្រសួង ក. បានឧបត្ថម្ភធនដើម្បីគាំទ្រដល់ការប្រព្រឹត្តទៅនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយពុំទទួលបានអ្វីតបស្នងវិញឡើយ។

**ស្ថាប័នសាធារណៈ** គឺសំដៅដល់រដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**ស្តុក** (Stock) សំដៅដល់ផលិតផលសម្រេចសម្រាប់លក់ ឬ ផ្គត់ផ្គង់ ចំណែកសន្និធិ សំដៅដល់ផលិតផលសម្រេចផងនិងវត្ថុធាតុដើមសម្រាប់ផលិតផង។ ជារួម ស្តុកទាំងអស់គឺជាសន្និធិ ប៉ុន្តែមិនមែនគ្រប់សន្និធិទាំងអស់គឺជាស្តុកទេ។

**សន្និធិ** គឺជាទ្រព្យសកម្ម៖

ក. ក្នុងទម្រង់ជាវត្ថុធាតុដើមសម្ភារ ឬ គ្រឿងផ្គត់ផ្គង់សម្ភារដែលត្រូវប្រើក្នុងដំណើរការផលិត ឬ ចែកចាយក្នុងការផ្តល់សេវា

ខ. ដែលបានរក្សាទុកសម្រាប់លក់ ឬ ចែកចាយក្នុងកិច្ចប្រតិបត្តិការធម្មតា

គ. ក្នុងដំណើរការផលិតសម្រាប់លក់ ឬ ចែកចាយ។

សន្និធិ ត្រូវបានដាក់បង្ហាញដោយឡែកពីគ្នានៅផ្នែកទ្រព្យសកម្ម នៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ស្ថាប័នសាធារណៈ។

# ជំពូកទី២
# ការទទួលស្គាល់និងការវាស់វែងសន្និធិ

ជាកិច្ចការចាំបាច់ និងមានសារៈសំខាន់ ក្នុងការទទួលស្គាល់និងការវាស់វែងសន្និធិឱ្យបានត្រឹមត្រូវនៅពេលដែលប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ដែលបណ្តាលឱ្យមានសន្និធិកើតឡើង។ សន្និធិ ត្រូវទទួលស្គាល់ស្របតាមគោលការណ៍សំខាន់ៗ នៃគណនេយ្យមូលដ្ឋានបង្គរ ដែលលក្ខខណ្ឌតម្រូវនៃការទទួលស្គាល់មានកំណត់នៅក្នុងស្តង់ដាដែលពាក់ព័ន្ធ។ ជំពូកទី២នេះ ត្រូវបានបែងចែកជាពីរផ្នែកៈ ផ្នែកទី១ កំណត់ពីលក្ខខណ្ឌ និងពេលវេលានៃការទទួលស្គាល់សន្និធិ និងផ្នែកទី២ កំណត់អំពីការវាស់វែង និងការគណនាថ្លៃដើមនៃសន្និធិ។

## ផ្នែកទី១
## ការទទួលស្គាល់សន្និធិ

សន្និធិអាចនឹងត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលស្ថាប័នសាធារណៈមានសិទ្ធិគ្រប់គ្រង និងចាត់ចែង និងទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាកម្ម។ សន្និធិក៏នឹងត្រូវទទួលស្គាល់ជាចំណាយថ្លៃដើមក្នុងរបាយការណ៍លទ្ធផលនៅពេលដែលសន្និធិត្រូវបានលក់ ប្តូរ ឬ ចែកចាយ។

**១. លក្ខខណ្ឌនៃការទទួលស្គាល់ជាទ្រព្យសកម្មរយៈពេលខ្លី**

ស្ថាប័នសាធារណៈត្រូវទទួលស្គាល់សន្និធិ ជាទ្រព្យសកម្ម នៅពេលបំពេញគ្រប់លក្ខខណ្ឌទាំងអស់ដូចខាងក្រោមៈ

ក. មានសិទ្ធិគ្រប់គ្រង និងចាត់ចែងលើសន្និធិ

ខ. ស្ថាប័នសាធារណៈទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាកម្មដែលអាចកើតឡើងពីសន្និធិ

គ. ថ្លៃដើមនៃសន្និធិអាចវាស់វែងបានប្រកបដោយភាពជឿជាក់។

**២. លក្ខខណ្ឌនៃការទទួលស្គាល់សន្និធិជាចំណាយថ្លៃដើម**

នៅពេលដែលសន្និធិត្រូវបានលក់ ប្តូរ ឬ ចែកចាយ តម្លៃយោងនៃសន្និធិទាំងនោះនឹងត្រូវបានទទួលស្គាល់ជាចំណាយថ្លៃដើម ស្របពេលដែលចំណូលពាក់ព័ន្ធនឹងការលក់សន្និធិត្រូវបានទទួលស្គាល់។

ករណីមិនមានការទទួលស្គាល់ចំណូល ចំណាយថ្លៃដើមសន្និធិត្រូវបានទទួលស្គាល់នៅពេលដែលទំនិញត្រូវបានចែកចាយ ឬ សេវាកម្មពាក់ព័ន្ធត្រូវបានផ្តល់។ ការធ្វើសំវិធានធន និងការខាតបង់ទាក់ទិននឹងសន្និធិទាំងអស់ នឹងត្រូវបានទទួលស្គាល់ជាចំណាយថ្លៃដើមក្នុងការិយបរិច្ឆេទ នៃការធ្វើសំវិធានធន និងការខាតបង់នោះកើតឡើង។

ការធ្វើប្រតិក្រាន្តនៃសំវិធានធនសន្និធិ នឹងត្រូវបានទទួលស្គាល់ជាការកាត់បន្ថយចំណាយថ្លៃដើមនៃសន្និធិក្នុងការិយបរិច្ឆេទ នៃការធ្វើប្រតិក្រាន្តនៃសំវិធានធនសន្និធិនោះកើតឡើង។

## ផ្នែកទី២
## ការវាស់វែងសន្និធិ

គោលបំណងចម្បងនៃការវាស់វែងសន្និធិ គឺការផ្គូផ្គងតួលេខចំណាយជាមួយនឹងចំណូលដែលពាក់ព័ន្ធដើម្បីគណនាប្រាក់ចំណូលសុទ្ធនៅក្នុងការរាយការណ៍ហិរញ្ញវត្ថុ។ គោលបំណងទីពីរនៃការវាស់វែងសន្និធិ ជាទូទៅដើម្បីធ្វើការបង្ហាញពីតួលេខតម្លៃនៃសន្និធិដល់ស្ថាប័នសាធារណៈ។ គោលបំណងទីបី គឺដើម្បីបង្ហាញព័ត៌មានទាក់ទិននឹងសន្និធិ ដែលអនុញ្ញាតឱ្យអ្នកគ្រប់គ្រង និងអ្នកប្រើប្រាស់ផ្សេងទៀតព្យាករណ៍លំហូរសាច់ប្រាក់នាពេលអនាគតរបស់ស្ថាប័នសាធារណៈ ដែលគោលបំណងទាំងនេះ នឹងអាចត្រូវបានអនុវត្តតាមទិដ្ឋភាពចំនួនពីរៈ ទីមួយ ចំនួនធនធានសន្និធិដែលមាននឹងគាំទ្រដល់លំហូរសាច់ប្រាក់តាមរយៈប្រតិបត្តិការលក់នៅក្នុងដំណើរការទូទៅនៃស្ថាប័ន។ ទីពីរ ចំនួនធនធានសន្និធិដែលមាន ជាធម្មតាក៏នឹងមានឥទ្ធិពលលើលំហូរសាច់ប្រាក់ដែលស្ថាប័នត្រូវការក្នុងអំឡុងពេលបន្ទាប់

ដើម្បីទិញទំនិញសម្រាប់ប្រតិបត្តិការលក់ក្នុងអំឡុងបន្ទាប់នេះផងដែរ។

**១. ការវាស់វែងសន្និធិ**

សន្និធិត្រូវវាស់វែងដោយយកតម្លៃទាបជាងគេរវាង៖

ក. ថ្លៃដើម និង

ខ. តម្លៃសុទ្ធដែលអាចទទួលបាន

**លើកលែងតែករណី៖**

ក. សន្និធិត្រូវបានទិញតាមរយៈប្រតិបត្តិការមិនដោះដូរ, ថ្លៃដើមនៃសន្និធិទាំងនោះត្រូវវាស់វែងតាមតម្លៃសមស្រប គិតត្រឹមកាលបរិច្ឆេទនៃការទិញ។

ខ. សន្និធិត្រូវវាស់វែងតាមថ្លៃដើមនិងថ្លៃដើមជំនួសបច្ចុប្បន្ន ដែលទាបជាង នៅពេលសន្និធិត្រូវបានរក្សាទុកសម្រាប់៖

(ក) ការចែកចាយ ដោយមិនគិតថ្លៃ ឬ គិតថ្លៃតិចតួច;

(ខ) ការប្រើប្រាស់ក្នុងដំណើរការផលិតទំនិញដែលត្រូវចែកចាយ ដោយមិនគិតថ្លៃ ឬ គិតថ្លៃតិចតួច។



## ២. ថ្លៃដើម

### ២.១ ធាតុនៃថ្លៃដើមសន្និធិ

ថ្លៃដើមសន្និធិរួមមាន៖ ការចំណាយទាំងអស់នៃការទិញ ការចំណាយនៃការបំប្លែង និងការចំណាយផ្សេងទៀត ដែលកើតឡើងក្នុងការនាំសន្និធិទៅកាន់ទីតាំង និងស្ថានភាពបច្ចុប្បន្ន។

**ចំណាយដែលរាប់បញ្ចូលជាថ្លៃដើមសន្និធិ**

| ចំណាយលើការទិញ | ចំណាយលើការបំប្លែង | ចំណាយផ្សេងៗ |
|---|---|---|
| • ថ្លៃដើមទិញ<br>• ពន្ធនាំចូល និងពន្ធផ្សេងទៀត<br>• ថ្លៃដឹកជញ្ជូន, ថ្លៃលើកដាក់ និងថ្លៃដើមផ្សេងទៀត<br>• អប្បហារពាណិជ្ជកម្ម, ការបង្វិលឱ្យវិញ និងធាតុប្រហាក់ប្រហែលផ្សេងទៀត ត្រូវបានកាត់ចេញក្នុងការកំណត់ថ្លៃដើមទិញ។ | • ថ្លៃដើមដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការផលិត<br>• ការបែងចែកនៃចំណាយថេរពាក់ព័ន្ធមិនផ្ទាល់ទៅនឹងការផលិត<br>• ចំណាយអថេរពាក់ព័ន្ធមិនផ្ទាល់ទៅនឹងការផលិត។ | • ចំណាយផ្សេងទៀតដែលកើតឡើងក្នុងការនាំសន្និធិទៅកាន់ទីតាំង និងស្ថានភាពបច្ចុប្បន្ន។<br>• បន្ទុកលើប្រាក់កម្ចី (ប្រសិនបើមានការកំណត់) |

**ចំណាយដែលមិនរាប់បញ្ចូលជាថ្លៃដើមសន្និធិ**

| ថ្លៃដើមតាមការិយបរិច្ឆេទ | ចំណាយការប្រាក់ |
|---|---|
| • ប្រហាក់ប្រហែលផ្សេងទៀតថ្លៃដើមផលិតកម្មដែលមិនប្រក្រតី<br>• ចំណាយក្នុងការស្តុកទំនិញ<br>• ចំណាយផ្នែករដ្ឋបាល<br>• ថ្លៃដើមលក់ | • ប្រសិនបើសន្និធិត្រូវបានទិញ ក្រោមលក្ខខណ្ឌពន្យារពេល ក្នុងការទូទាត់ ភាពខុសគ្នារវាងតម្លៃទិញសម្រាប់លក្ខខណ្ឌឥណទានធម្មតា និងចំនួនទឹកប្រាក់ដែលបានទូទាត់ ត្រូវបានទទួលស្គាល់ជាចំណាយការប្រាក់ ក្នុងរយៈពេលនៃការផ្តល់ហិរញ្ញប្បទាន។ |

**ក. ចំណាយលើការទិញ**

ចំណាយលើការទិញសន្និធិរួមមានៈ

(ក) ថ្លៃដើមទិញ

(ខ) ពន្ធនាំចូល និងពន្ធផ្សេងទៀត

(គ) ថ្លៃដឹកជញ្ជូន, ថ្លៃលើកដាក់ និងថ្លៃដើមផ្សេងទៀត។ ដោយឡែក អប្បហារពាណិជ្ជកម្ម ការបង្វិលឱ្យវិញ និងធាតុប្រហាក់ប្រហែលផ្សេងទៀតត្រូវបានកាត់ចេញក្នុងការកំណត់ថ្លៃដើមទិញ។

ឧទាហរណ៍៖ ចំណាយលើការទិញសន្និធិ

ស្ថាប័នសាធារណៈ (ក) ទិញគ្រាប់ពូជស្រូវ ១០ តោន សម្រាប់លក់បន្ត ដោយតម្លៃ ៧០ លានរៀល បង់ថ្លៃដឹកជញ្ជូន ៥ លានរៀល និង ចំណាយលើការបង់ពន្ធចំនួន ៥ លានរៀល។

ចំណាយលើការទិញសរុប = ៧០+៥+៥ លានរៀល = ៨០ លានរៀល។

**ខ. ចំណាយលើការបំប្លែង**

ចំណាយលើការបំប្លែង(វត្ថុធាតុដើម ឬ សន្និធិដែលកំពុងដំណើរការបំប្លែងទៅជាផលិតផលសម្រេច) រួមមានៈ

(ក) ថ្លៃដើមដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងចំនួនឯកតាផលិត ដូចជា កម្លាំងពលកម្មផ្ទាល់។

(ខ) ថ្លៃដើមពីការវិភាជន៍ជាលក្ខណៈប្រព័ន្ធនៃចំណាយផលិតកម្មថេរនិងចំណាយផលិតកម្មអថេរ ដែលបានកើតឡើងក្នុងការបំប្លែងសម្ភារទៅជាទំនិញសម្រេច។ ចំណាយផលិតកម្មថេររួមមាន៖ ចំណាយរំលស់ និងចំណាយថែទាំអគារ និងបរិក្ខាររោងចក្រ ។ ចំណាយផលិតកម្មថេរ គឺជាថ្លៃដើមផលិតទាំងឡាយណាដែលប្រែប្រួលដោយផ្ទាល់ ឬ ស្ទើរតែដោយផ្ទាល់ទៅនឹងទំហំផលិតកម្ម ដូចជា សម្ភារ និងកម្លាំងពលកម្មប្រយោល។

ការធ្វើវិភាជន៍ចំណាយផលិតកម្មថេរ ទៅក្នុងថ្លៃដើមបំប្លែង គឺផ្អែកលើសមត្ថភាពធម្មតានៃបរិក្ខារផលិតកម្ម សមត្ថភាពធម្មតា គឺជាផលិតកម្មដែលបានរំពឹងទុកថាអាចសម្រេចបាន។ ចំណាយដែលមិនបានធ្វើវិភាជន៍ ត្រូវទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលចំណាយទាំងនោះបានកើតឡើង។ ក្នុងការិយបរិច្ឆេទដែលផលិតកម្មមានកំណើនខ្ពស់ខុសពីធម្មតា ចំនួនទឹកប្រាក់នៃចំណាយផលិតកម្មថេរដែលបានធ្វើវិភាជន៍ទៅកាន់ឯកតាផលិតនីមួយៗ ត្រូវបានថយចុះ ដូចនេះ សន្និធិមិនត្រូវបានវាស់វែងលើសថ្លៃដើមនោះទេ។ ចំណាយផលិតកម្មអថេរ ត្រូវបានធ្វើវិភាជន៍ទៅកាន់ឯកតាផលិតនីមួយៗ ដោយផ្អែកលើមូលដ្ឋាននៃការប្រើប្រាស់បរិក្ខារផលិតកម្មជាក់ស្តែង។

ក្នុងករណីដែលដំណើរការផលិតកម្មសម្រាប់ផលិតទំនិញច្រើនមុខ ឧទាហរណ៍ ការផលិតទំនិញច្រើនមុខរួមគ្នាក្នុងពេលតែមួយ ឬ ការផលិតទំនិញមេមួយ និងទំនិញបន្ទាប់បន្សំក្នុងពេលតែមួយ ដែលថ្លៃដើមបំប្លែងនៃផលិតផលនីមួយៗមិនអាចកំណត់អត្តសញ្ញាណដាច់ដោយឡែកពីគ្នាបាន ក្នុងករណីនេះ ថ្លៃដើមបំប្លែងទំនិញមេ ត្រូវវាស់វែងតាមតម្លៃសុទ្ធដែលអាចទទួលបាន ចំណែកថ្លៃដើមបំប្លែងទំនិញបន្ទាប់បន្សំត្រូវវាស់វែងតាមតម្លៃសុទ្ធដែលអាចទទួលបានដោយការធ្វើវិភាជន៍នៃតម្លៃសុទ្ធដែលអាចទទួលបានរបស់ទំនិញមេ។

ឧទាហរណ៍៖ ចំណាយបំប្លែង

ស្ថាប័នសាធារណៈ (ក) ទិញរថយន្តដឹកទំនិញចំនួន ១០ គ្រឿង សម្រាប់លក់បន្ត ដោយតម្លៃ ៤០០ លានរៀល រថយន្តទាំងនេះត្រូវការផ្លាស់ប្តូរកង់មុនពេលអាចប្រើប្រាស់និងលក់បាន។ ចំណាយដូរកង់ថ្មីក្នុងឡានមួយអស់ថ្លៃចំនួន ១ លានរៀល។

ចំណាយថ្លៃដើមឡានដឹកទំនិញ = ៤០០+១០ លានរៀល = ៤១០ លានរៀល។

### គ. ថ្លៃដើមផ្សេងទៀត

ថ្លៃដើមផ្សេងទៀត ត្រូវបានរួមបញ្ចូលក្នុងថ្លៃដើមសន្និធិ តែក្នុងវិសាលភាពដែលថ្លៃដើមទាំងនោះត្រូវបានកើតឡើង ក្នុងការនាំយកសន្និធិទៅកាន់ទីតាំងនិងលក្ខខណ្ឌបច្ចុប្បន្នរបស់សន្និធិទាំងនោះប៉ុណ្ណោះ។ ឧទាហរណ៍ ចំណាយមិនមែនផលិតកម្ម ឬ ថ្លៃដើមនៃការរចនាផលិតផលតាមការចង់បានរបស់អតិថិជនជាពិសេស ត្រូវបានរាប់បញ្ចូលទៅក្នុងថ្លៃដើមសន្និធិ។

ចំណាយដែលមិនរាប់បញ្ចូលក្នុងថ្លៃដើមសន្និធិរួមមាន៖

(ក) ចំណាយលើភាពមិនប្រក្រតីនៃសម្ភារដែលបានខ្ជះខ្ជាយ, កម្លាំងពលកម្ម ឬ ថ្លៃដើមផលិតផ្សេងទៀត

(ខ) ថ្លៃដើមក្នុងការរក្សាទុក លុះត្រាតែថ្លៃដើមទាំងនោះមានភាពចាំបាច់ក្នុងដំណើរការផលិត មុនពេលដំណាក់កាលផលិតកម្មបន្ទាប់

(គ) ចំណាយរដ្ឋបាលដែលមិនរួមចំណែកក្នុងការនាំយកសន្និធិទៅកាន់ទីតាំងនិងលក្ខខណ្ឌបច្ចុប្បន្នរបស់សន្និធិទាំងនោះ និង

(ឃ) ថ្លៃដើមលក់

បន្ទុកលើប្រាក់កម្ចី សម្រាប់សន្និធិដែលត្រូវការពេលច្រើនក្នុងការនាំយកសន្និធិទៅកាន់ទីតាំង និងលក្ខខណ្ឌបច្ចុប្បន្នរបស់សន្និធិទាំងនោះដើម្បីប្រើប្រាស់ ឬ លក់ត្រូវបានរួមបញ្ចូលនៅក្នុងថ្លៃដើមនៃសន្និធិ។

ក្នុងករណី ស្ថាប័នសាធារណៈទិញសន្និធិក្នុងលក្ខខណ្ឌពន្យារការទូទាត់ ជាតុហិរញ្ញប្បទានណាមួយលើសន្និធិដែលបានទិញក្រោមលក្ខខណ្ឌទូទាត់ពន្យារពេល (ឧទាហរណ៍ ទឹកប្រាក់ខុសគ្នារវាងតម្លៃទិញសម្រាប់លក្ខខណ្ឌឥណទានធម្មតា និងចំនួនទឹកប្រាក់ដែលបានបង់) ត្រូវបានទទួលស្គាល់ជាចំណាយការប្រាក់ក្នុងរយៈពេលនៃការផ្តល់ហិរញ្ញប្បទាន។

### ២.២ ថ្លៃដើមសន្និធិរបស់អ្នកផ្តល់សេវា

អ្នកផ្តល់សេវា គឺជាស្ថាប័នសាធារណៈដែលផ្តល់សេវាកម្មដល់ស្ថាប័នផ្សេងទៀតជាថ្នូរនឹងការទូទាត់។ សន្និធិរបស់អ្នកផ្តល់សេវាត្រូវបានវាស់វែងតាមតម្លៃនៃការផលិតរបស់ពួកគេ។ ថ្លៃដើមនៃការផលិតរួមមាន៖ថ្លៃពលកម្ម និងថ្លៃដើមផ្សេងទៀតរបស់បុគ្គលិកដែលពាក់ព័ន្ធដោយផ្ទាល់ក្នុងការផ្តល់សេវាកម្ម។ ចំណាយរបស់បុគ្គលិកត្រួតពិនិត្យ និងចំណាយបន្ទាប់បន្សំក៏រាប់បញ្ចូលជាផ្នែកមួយនៃថ្លៃដើមនៃការផលិតផងដែរ។ ថ្លៃដើមពលកម្មនិងថ្លៃដើមផ្សេងទៀតដែលជាប់ពាក់ព័ន្ធនឹងការលក់ និងបុគ្គលរដ្ឋបាលទូទៅ មិនត្រូវបានរាប់បញ្ចូលនោះទេ ប៉ុន្តែត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលថ្លៃដើមទាំងនោះបានកើតឡើង។ ថ្លៃដើមសន្និធិរបស់អ្នកផ្តល់សេវា មិនរាប់បញ្ចូលប្រាក់ចំណេញដុល ឬ ចំណាយដែលមិនចាត់ជាចំណាយបន្ទាប់បន្សំ(ចំណាយនេះជាទូទៅតែងតែត្រូវបានរាប់បញ្ចូលជាតម្លៃដែលបានគិតថ្លៃដោយអ្នកផ្តល់សេវា)។

### ២.៣ ថ្លៃដើមផលិតផលកសិកម្មដែលបានច្រូតកាត់ពីទ្រព្យសកម្មជីវសាស្ត្រ

ផលិតផល ឬ ការប្រមូលផលពីទ្រព្យជីវសាស្ត្រ (ឧទាហរណ៍ ទឹកដោះគោ សាច់គោ ស្លឹកតែ ផ្លែឈើ គ្រាប់កាហ្វេ និងឈើ) គឺជាសន្និធិ។ សន្និធិ រាប់បញ្ចូលទាំងផលិតផលកសិកម្មដែលប្រមូលផលពីទ្រព្យជីវសាស្ត្រ នៃស្ថាប័នសាធារណៈត្រូវវាស់វែងក្នុងការទទួលស្គាល់ដំបូងតាមតម្លៃសមរម្យ និងដកចេញចំណាយថ្លៃលក់នៅពេលប្រមូលផល។ ប៉ុន្តែ ចំពោះផលិតផលកសិកម្មដែលនៅកំពុងតែដាំដុះ ឬ នៅតែភ្ជាប់ទៅនឹងទ្រព្យសម្បត្តិជីវសាស្ត្រ ផលិតផលកសិកម្មនោះមិនត្រូវចាត់ជាសន្និធិទេ តែត្រូវចាត់ទុកជាផ្នែកមួយនៃតម្លៃនៃទ្រព្យសម្បត្តិជីវសាស្ត្រ នឹងត្រូវអនុវត្តស្របតាមស្តង់ដាគណនេយ្យស្តីពីទ្រព្យ រោងចក្រ និងបរិក្ខារ។

### ២.៤ វិធីសាស្ត្រវាស់វែងថ្លៃដើម

វិធីសាស្ត្រវាស់វែងថ្លៃដើមរួមមាន៖

(ក) វិធីសាស្ត្រសម្រាប់ការវាស់វែងថ្លៃដើមសន្និធិ ដូចជា វិធីសាស្ត្រថ្លៃដើមបទដ្ឋាន អាចត្រូវបានប្រើដើម្បីផ្តល់ភាពងាយស្រួល ប្រសិនបើលទ្ធផលអាចស្មើនឹងថ្លៃដើម។ ថ្លៃដើមបទដ្ឋាន ពិចារណាទៅលើកម្រិតធម្មតា នៃសម្ភារនិងគ្រឿងផ្គត់ផ្គង់ កម្លាំងពលកម្ម ស័ក្តិសិទ្ធភាព និងការប្រើប្រាស់សមត្ថភាព។ ថ្លៃដើមបទដ្ឋានត្រូវបានត្រួតពិនិត្យជាទៀងទាត់ ហើយត្រូវបានកែសម្រួលតាមភាពចាំបាច់ដោយផ្អែកលើលក្ខខណ្ឌបច្ចុប្បន្ន។

(ខ) សន្និធិអាចត្រូវបានផ្ទេរទៅកាន់ស្ថាប័នសាធារណៈ តាមរយៈប្រតិបត្តិការមិនដោះដូរ។ ក្នុងករណីនេះ ថ្លៃដើមសន្និធិ គឺជាតម្លៃសមស្របរបស់សន្និធិ គិតត្រឹមកាលបរិច្ឆេទដែលសន្និធិនោះត្រូវបានទិញ។

### ២.៥ វិធីសាស្ត្រគណនាថ្លៃដើម

ថ្លៃដើមសន្និធិនៃធាតុដែលជាធម្មតាមិនអាចដោះដូរទៅវិញទៅមកបាន ទំនិញ ឬ សេវាដែលត្រូវបានផលិត និងបានញែកដាច់ដោយឡែកពីគ្នាសម្រាប់គម្រោងជាក់លាក់ ត្រូវបានកំណត់ដោយប្រើវិធីសាស្ត្រ"វិធីសាស្ត្រចូលមុន-ចេញមុន" (FIFO) ឬវិធីសាស្ត្រមធ្យមទម្ងន់(Weight average)។ "វិធីសាស្ត្រចូលមុន-ចេញមុន" សន្មត់ថាសន្និធិដែលត្រូវបានទិញដំបូងត្រូវបានលក់ចេញវិញមុន ដូចនេះ សន្និធិដែលនៅសល់ ត្រូវកំណត់ថ្លៃដើមតាមតម្លៃថ្មីចុងក្រោយបំផុត។ ចំពោះវិធីសាស្ត្រមធ្យមទម្ងន់ ថ្លៃដើមទំនិញនីមួយៗត្រូវបានកំណត់តាមមធ្យមភាគថេរស្មើៗគ្នា នៃតម្លៃនៃទំនិញស្រដៀងគ្នានៅដើមគ្រា និងថ្លៃដើមទំនិញស្រដៀងគ្នាដែលបានទិញ ឬ ផលិតក្នុងគ្រា។ ជាទូទៅ វិធីសាស្ត្រមធ្យមទម្ងន់អាចត្រូវបានគណនាក្នុងរយៈកាលមួយកំណត់ អាស្រ័យតាមការកំណត់របស់ស្ថាប័នសាធារណៈ។

**ឧទាហរណ៍ទី១៖ វិធីសាស្ត្រគណនាថ្លៃដើម "វិធីសាស្ត្រចូលមុន-ចេញមុន" (FIFO)**

នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០X៣ ស្ថាប័នសាធារណៈ(ក) បានទិញស្រូវពូជ ចំនួន ១០តោន ពីពាណិជ្ជករដែលមានតម្លៃជាទឹកប្រាក់ចំនួន៨០ ០០០ ០០០រៀល និង នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០X៣ បន្តទិញស្រូវពូជថែមចំនួន ១០តោន ទៀតមានតម្លៃជាទឹកប្រាក់ចំនួន៩០ ០០០ ០០០រៀល។ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០X៣ ស្ថាប័នសាធារណៈ(ក) បានលក់ស្រូវពូជ ចំនួន ១០ តោនចេញវិញដោយយកស្រូវពូជដែលទិញកាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០X៣ មានថ្លៃដើម៨០ ០០០ ០០០រៀល។

**ឧទាហរណ៍ទី២៖ វិធីសាស្ត្រគណនាថ្លៃដើម "វិធីសាស្ត្រមធ្យមទម្ងន់" (Weight average)**

នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០X២ ស្ថាប័នសាធារណៈ(ក) បានទិញវ៉ាក់សាំងសម្រាប់ផ្តល់ជូនប្រជាជនដោយមិនគិតថ្លៃ ចំនួន ២០ ០០០ ដូស ដែលមានតម្លៃជាទឹកប្រាក់ចំនួន៨ ០០០ ០០០រៀល បង់ថ្លៃដឹកជញ្ជូនចំនួន ២ ០០០ ០០០រៀល និងចំណាយផ្សេងៗចំនួន ១ ០០០ ០០០រៀល។ ការទូទាត់ប្រាក់ធ្វើនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០X២។ ថ្លៃដើមវ៉ាក់សាំង =៨+ ២+ ១= ១១លានរៀល ដូចនេះថ្លៃដើមវ៉ាក់សាំងក្នុង១ដូសមានតម្លៃថ្លៃដើមស្មើៗគ្នាគឺ ១១លានរៀល៖ ២០ ០០០ដូស= ៥៥០ រៀល។

### ២.៦ តម្លៃសុទ្ធដែលអាចទទួលបាន

ប្រសិនបើ តម្លៃលក់នៃសន្និធិបានធ្លាក់ចុះនឹងប្រហែលជាមិនអាចមានតម្លៃស្មើថ្លៃដើមវិញទេ សន្និធិនោះត្រូវទម្លាក់ថ្លៃមកក្រោមថ្លៃដើម ដោយធ្វើការវាស់វែងតាមតម្លៃសុទ្ធដែលអាចទទួលបានក្នុងករណី៖

(ក) សន្និធិទាំងនោះត្រូវបានខូចខាត

(ខ) សន្និធិទាំងនោះលែងប្រើការបានទាំងស្រុង ឬ ប្រើប្រាស់បានដោយផ្នែក

(គ) តម្លៃលក់របស់សន្និធិទាំងនោះបានធ្លាក់ចុះ

(ឃ) ថ្លៃដើមប៉ាន់ស្មាននៃសន្និធិដើម្បីអាចលក់ ដោះដូរ ឬ ចែកចាយ បានកើនឡើង។

សន្និធិត្រូវទម្លាក់ថ្លៃមកក្រោមថ្លៃដើម នឹងវាស់វែងតាមតម្លៃសុទ្ធដែលអាចទទួលបានតាមប្រភេទនីមួយៗ

**២.៧ ការចែកចាយសន្និធិដោយមិនគិតថ្លៃ ឬ គិតថ្លៃតិចតួច**

ក្នុងករណីដែលស្ថាប័នសាធារណៈ រក្សាទុកសន្និធិក្នុងគោលបំណងចែកចាយដោយមិនគិតថ្លៃ ឬ គិតថ្លៃបន្តិចបន្តួច តម្លៃសុទ្ធដែលអាចទទួលបានត្រូវវាស់វែងតាមថ្លៃដើមជំនួសបច្ចុប្បន្ន។ ប៉ុន្តែ ប្រសិនបើគោលបំណងក្នុងការរក្សាទុកសន្និធិមានការផ្លាស់ប្តូរពីគោលបំណងខាងលើនេះទេ ថ្លៃដើមសន្និធិត្រូវយកតាមវិធីសាស្ត្រក្នុងចំនុចទី ២. ថ្លៃដើម។

# ជំពូកទី៣

## គណនេយ្យកម្មសន្និធិ

ស្ថាប័នសាធារណៈត្រូវទទួលស្គាល់សន្និធិ ជាទ្រព្យសកម្មរយៈពេលខ្លីក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងទទួលស្គាល់សន្និធិ ជាចំណាយថ្លៃដើមក្នុងរបាយការណ៍លទ្ធផលហិរញ្ញវត្ថុដូចខាងក្រោម៖

**១. លក្ខខណ្ឌនៃការទទួលស្គាល់សន្និធិ**

ចំពោះការធ្វើគណនេយ្យកម្មទិញសន្និធិ ការទិញសន្និធិត្រូវបានឆ្លុះបញ្ចាំងជាទ្រព្យសកម្មរយៈពេលខ្លី ព្រោះជាធម្មតា សន្និធិត្រូវលក់ចេញវិញក្នុងកំឡុងពេលនៃការិយបរិច្ឆេទរយៈពេលមួយឆ្នាំ។ នៅក្នុងវិធីសាស្ត្រចុះបញ្ជិកាទ្វេភាគ សន្និធិដែលទិញក្រោមរូបភាពឥណទានរង់ចាំការទូទាត់ ក៏ត្រូវកត់ត្រាជាគណនីដែលត្រូវសង ឬ កាតព្វកិច្ចហិរញ្ញវត្ថុរយៈពេលខ្លីដើម្បីរង់ចាំទូទាត់ដល់អ្នកផ្គត់ផ្គង់ផងដែរ។ ស្ថាប័នសាធារណៈត្រូវទទួលស្គាល់សន្និធិទាក់ទិននឹងការទិញទំនិញ និងសេវាកម្មនៅពេលបំពេញលក្ខខណ្ឌដូចខាងក្រោម៖

(ក) មានសិទ្ធិគ្រប់គ្រង និងចាត់ចែងលើសន្និធិ

(ខ) ស្ថាប័នសាធារណៈទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាកម្មដែលអាចកើតឡើងពីសន្និធិ

(គ) ថ្លៃដើមនៃសន្និធិអាចវាស់វែងបានប្រកបដោយភាពជឿជាក់។

**ឧទាហរណ៍ទី១៖ ការទិញស្រូវពូជ**

នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០X២ ស្ថាប័នសាធារណៈ(ក) បានទិញស្រូវពូជសម្រាប់យកមកផលិតលក់ ចំនួន ១០តោន ពីពាណិជ្ជករ និងបានទទួលស្រូវពូជពីពាណិជ្ជករដែលមានតម្លៃជាទឹកប្រាក់ចំនួន៨០ ០០០ ០០០រៀល និងបានទូទាត់ប្រាក់នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០X២។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី១. នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០X២ ទទួលស្គាល់សន្និធិជាទ្រព្យសកម្មរយៈពេលខ្លី** | | |
| ឥណពន្ធ គណនី ពូជនិងកូនរុក្ខជាតិ | ១៧០៣៣ | ៨០ ០០០ ០០០ |
| ឥណទាន គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ៨០ ០០០ ០០០ |

នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០X២ ស្ថាប័នសាធារណៈ(ក)បានទូទាត់សាច់ប្រាក់៨០ ០០០ ០០០រៀល ជូនពាណិជ្ជករសម្រាប់ការទិញស្រូវពូជដែលបានដឹកជញ្ជូនរួចរាល់។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី២. នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០X២ ពេលទូទាត់ប្រាក់** | | |
| ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ៨០ ០០០ ០០០ |
| ឥណទាន គណនី ធនាគារ | ១១.... | ៨០ ០០០ ០០០ |

**ឧទាហរណ៍ទី២៖ ការទិញវ៉ាក់សាំង**

នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០X២ ស្ថាប័នសាធារណៈ(ក) បានទិញវ៉ាក់សាំងសម្រាប់ផ្តល់ជូនប្រជាជនដោយមិនគិតថ្លៃ ចំនួន ២០ ០០០ ដូស ដែលមានតម្លៃជាទឹកប្រាក់ចំនួន៨ ០០០ ០០០រៀល បង់ថ្លៃដឹកជញ្ជូនចំនួន

២ ០០០ ០០០រៀល និងចំណាយផ្សេងៗចំនួន ១ ០០០ ០០០រៀល។ ការទូទាត់ប្រាក់ធ្វើនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០X២។

ថ្លៃដើមវ៉ាក់សាំង =៨+ ២+ ១= ១១លានរៀល

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី១. នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០X២ ទទួលស្គាល់សន្និធិជាទ្រព្យសកម្មរយៈពេលខ្លី** | | |
| ឥណពន្ធ គណនី សម្ភារបរិក្ខារពេទ្យ | ១៧០៧២ | ១១ ០០០ ០០០ |
| ឥណទាន គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ១១ ០០០ ០០០ |
| **២. នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០X២ ពេលទូទាត់ប្រាក់** | | |
| ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ១១ ០០០ ០០០ |
| ឥណទាន គណនី ធនាគារ | ១១.... | ១១ ០០០ ០០០ |

**២. លក្ខខណ្ឌនៃការទទួលស្គាល់ជាចំណាយថ្លៃដើម**

ស្ថាប័នសាធារណៈត្រូវកត់ត្រាទទួលស្គាល់សន្និធិជាចំណាយថ្លៃដើម នៅពេលដែលសន្និធិត្រូវបានលក់ ឬ ចែកចាយ។ ចំណាយថ្លៃដើមនេះត្រូវទទួលស្គាល់ ស្របពេលដែលមានការទទួលស្គាល់ប្រតិបត្តិការលក់ និងការទទួលស្គាល់ចំណេញពីការលក់សន្និធិនេះផងដែរ។ តម្លៃសន្និធិដែលជាទ្រព្យសកម្មរយៈពេលខ្លី នឹងត្រូវផ្ទេរទៅជាចំណាយថ្លៃដើមនៃទំនិញដែលបានលក់។

**ឧទាហរណ៍ទី១៖ ការលក់ស្រូវពូជ**

នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០X៣ ស្ថាប័នសាធារណៈ(ក) បានលក់ស្រូវពូជ ចំនួន ១០តោន ជូនពាណិជ្ជករដែលមានតម្លៃជាទឹកប្រាក់ចំនួន៩០ ០០០ ០០០រៀល និងបានទូទាត់ប្រាក់នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០X៣។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី១. នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០X៣ ទទួលស្គាល់ការលក់** | | |
| ឥណពន្ធ គណនី អតិថិជន (ចំណូលមិនមែនសារពើពន្ធ) | ១៥០២ | ៩០ ០០០ ០០០ |
| ឥណទាន គណនី ការលក់ផលិតផលកសិកម្ម | ៧៣០១៤ | ៩០ ០០០ ០០០ |
| **ទី២. នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០X៣ ផ្ទេរសន្និធិមកជាចំណាយថ្លៃដើម** | | |
| ឥណពន្ធ គណនី ពូជនិងកូនរុក្ខជាតិ | ៦០០៣៣ | ៨០ ០០០ ០០០ |
| ឥណទាន គណនី ពូជនិងកូនរុក្ខជាតិ | ១៧០៣៣ | ៨០ ០០០ ០០០ |

នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០X២ ស្ថាប័នសាធារណៈ(ក)បានទទួលសាច់ប្រាក់ចំនួន៩០ ០០០ ០០០រៀល ពីពាណិជ្ជករសម្រាប់ការលក់ស្រូវពូជដែលបានដឹកជញ្ជូនរួចរាល់។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី៣. នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០X២ ពេលទូទាត់ប្រាក់** | | |
| ឥណពន្ធ គណនី ធនាគារ | ១១.... | ៩០ ០០០ ០០០ |
| ឥណទាន គណនី អតិថិជន (ចំណូលមិនមែនសារពើពន្ធ) | ១៥០២ | ៩០ ០០០ ០០០ |

**ឧទាហរណ៍ទី២៖ ការចែកចាយវ៉ាក់សាំង**

នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០X២ ស្ថាប័នសាធារណៈ(ក) បានចែកវ៉ាក់សាំងជូនប្រជាជនដោយមិនគិតថ្លៃ ចំនួន ២០ ០០០ ដូស ដែលមានតម្លៃជាទឹកប្រាក់ចំនួន១១ ០០០ ០០០រៀល។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០X២ ផ្ទេរសន្និធិមកជាចំណាយថ្លៃដើម** | | |
| ឥណពន្ធ គណនី សម្ភារបរិក្ខារពេទ្យ | ៦០០៧២ | ១១ ០០០ ០០០ |
| ឥណទាន គណនី សម្ភារបរិក្ខារពេទ្យ | ១៧០៧២ | ១១ ០០០ ០០០ |

## ជំពូកទី៤
## ការឈប់ទទួលស្គាល់សន្និធិ

ការឈប់ទទួលស្គាល់សន្និធិ នឹងត្រូវធ្វើឡើងតាមរយៈការលុបចេញ ឬ ការបន្ថយតម្លៃសន្និធិ។ ការលុបសន្និធិចេញ គឺជាដំណើរការនៃការដកធាតុសន្និធិចេញពីបញ្ជីស្តុកដែលមានបច្ចុប្បន្ន។ ចំពោះការបន្ថយតម្លៃសន្និធិ ធ្វើឡើងក្នុងករណីសន្និធិនោះមានការខូតខាត ឬ បាត់បង់អត្ថប្រយោជន៍សេដ្ឋកិច្ចដោយផ្នែក ប៉ុន្តែសន្និធិនោះនៅតែអាចប្រើប្រាស់ និងលក់បាន។

**១. លក្ខខណ្ឌនៃការឈប់ទទួលស្គាល់សន្និធិ**

ស្ថាប័នសាធារណៈ ត្រូវឈប់ទទួលស្គាល់សន្និធិពីបញ្ជីគណនេយ្យក្នុងករណីដូចខាងក្រោម៖

ក. ការលុបសន្និធិចេញ៖ ធ្វើនៅពេលដែលសន្និធិមិនអាចលក់បាន ដោយសារមានការខូចខាតខ្លាំង បាត់បង់អត្ថប្រយោជន៍សេដ្ឋកិច្ច ត្រូវបានលួចបាត់ ឬ ហួសសម័យ។

ខ. ការបន្ថយតម្លៃសន្និធិ៖ អាចធ្វើឡើងក្រោមលក្ខខណ្ឌនីមួយៗដូចខាងក្រោម៖

(ក) សន្និធិ ជាផលិតផលចាស់ នឹងលែងមានតម្លៃលក់ដូចគ្នាបើធៀបនឹងផលិតផលទើបផលិតថ្មីដែលកំពុងដាក់លក់លើទីផ្សារ។ ដូចនេះការបន្ថយតម្លៃសន្និធិត្រូវធ្វើឡើងដើម្បីទទួលស្គាល់ការខាតបង់តម្លៃរបស់សន្និធិដែលស្ថាប័នសាធារណៈកំពុងកាន់កាប់។

(ខ) តម្លៃទីផ្សាររបស់សន្និធិបានធ្លាក់ថ្លៃដោយសារការមានការផ្គត់ផ្គង់លើសតម្រូវការ ដូចនេះការបន្ថយតម្លៃសន្និធិត្រូវធ្វើឡើងដើម្បីទទួលស្គាល់តម្លៃទីផ្សាររបស់សន្និធិដែលស្ថាប័នសាធារណៈកំពុងកាន់កាប់។

(គ) ការកត់ត្រាតម្លៃសន្និធិមិនត្រឹមត្រូវ ហើយចង់ធ្វើបច្ចុប្បន្នភាពតម្លៃសន្និធិឡើងវិញដើម្បីធានាថាមិនមានការខុសឆ្គងត្រូវបានធ្វើឡើងនោះទេ។ ការបន្ថយតម្លៃសន្និធិក៏អាចកើតឡើងដោយសារការធ្វើបច្ចុប្បន្នភាព និងការសើរើឡើងវិញនូវកិច្ចសន្យានានា ដែលផ្តល់សិទ្ធិឱ្យភាគីអ្នកបង់ប្រាក់នូវជម្រើសមិនបង់សមតុល្យទាំងមូល ឬ ជាផ្នែក។

**២. គណនេយ្យកម្មនៃការឈប់ទទួលស្គាល់សន្និធិ**

**ឧទាហរណ៍ទី១៖ ការលុបសន្និធិចេញ**

នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០X៣ ស្ថាប័នសាធារណៈ(ក) បានទិញស្រូវពូជសម្រាប់យកមកផលិតលក់ ចំនួន ១០តោន ពីពាណិជ្ជករ និងបានទទួលស្រូវពូជពីពាណិជ្ជករដែលមានតម្លៃជាទឹកប្រាក់ចំនួន៩០ ០០០ ០០០រៀល។ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០X៤ ស្ថាប័នសាធារណៈ(ក) បានពិនិត្យឃើញថាស្រូវពូជ ចំនួន ២តោន បានខូចខាត និងមិនអាចលក់បានដែលមានតម្លៃជាទឹកប្រាក់ចំនួន១៨ ០០០ ០០០រៀល។ ដូចនេះការចុះបញ្ជិកាគណនេយ្យក្នុងការលុបសន្និធិដែលខូចចេញមានដូចតទៅ៖

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០X៤ លុបសន្និធិចេញមកជាចំណាយថ្លៃដើម** | | |
| ឥណពន្ធ គណនី ពូជនិងកូនរុក្ខជាតិ | ៦០០៣៣ | ១៨ ០០០ ០០០ |
| ឥណទាន គណនី ពូជនិងកូនរុក្ខជាតិ | ១៧០៣៧ | ១៨ ០០០ ០០០ |

**ឧទាហរណ៍ទី២៖ ការបន្ថយតម្លៃសន្និធិ**

នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០X៣ ស្ថាប័នសាធារណៈ(ក) បានទិញស្រូវពូជសម្រាប់យកមកផលិតលក់ ចំនួន ១០តោន ពីពាណិជ្ជករ និងបានទទួលស្រូវពូជពីពាណិជ្ជករដែលមានតម្លៃជាទឹកប្រាក់ចំនួន៩០ ០០០ ០០០រៀល។ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០X៤ ស្ថាប័នសាធារណៈ(ក) បានពិនិត្យឃើញថាស្រូវពូជដែលបានទិញ ចំនួន ១០តោន នោះបានធ្លាក់ចុះគុណភាព តែនៅអាចដាក់លក់បានដោយបន្ថយតម្លៃចំនួន២ ០០០ ០០០រៀល ក្នុង ១តោន។ ដូចនេះ ការចុះបញ្ជិកាគណនេយ្យក្នុងការបន្ថយតម្លៃសន្និធិដែលធ្លាក់ចុះគុណភាពមានដូចតទៅ៖

**កិច្ចបញ្ជិកាគណនេយ្យ**

| | **មាតិកាគណនី** | **ចំនួនជារៀល** |
|---|---|---|
| **នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០X៤ បន្ថយតម្លៃសន្និធិ** | | |
| ឥណពន្ធ គណនី ពូជនិងកូនរុក្ខជាតិ | ៦០០៣៣ | ២០ ០០០ ០០០ |
| ឥណទាន គណនី ពូជនិងកូនរុក្ខជាតិ | ១៧០៣៣ | ២០ ០០០ ០០០ |

# ជំពូកទី៥
# វិធីដំណើរការនិងការរាយការណ៍សន្និធិ

ជំពូកនេះបង្ហាញភាគីពាក់ព័ន្ធសំខាន់ៗ វិធីដំណើរការ និង ឯកសារតម្រូវសម្រាប់ការទទួលស្គាល់សន្និធិ ការកត់ត្រាទទួលស្គាល់ជាចំណាយ និងការរាយការណ៍សន្និធិ។

**១.ភាគីពាក់ព័ន្ធ**

ក. អ្នកផ្គត់ផ្គង់ ទាំងនិវាសនជន និងអនិវាសជន ដែលជាអ្នកមានកាតព្វកិច្ចផ្គត់ផ្គង់ទំនិញនិងសេវាកម្មដល់រាជរដ្ឋាភិបាល។ អ្នកផ្គត់ផ្គង់ ក៏រួមបញ្ចូលមន្ត្រីដែលបម្រើការនៅក្នុងរាជរដ្ឋាភិបាលផងដែរ។

ខ. អគ្គនាយកដ្ឋានរតនាគារជាតិ(GDNT) គឺជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើរតួនាទីជាគណនេយ្យករ និងបេឡាករ ក្នុងបេសកកម្មរៀបចំកិច្ចបញ្ជិកាគណនេយ្យរបស់រដ្ឋ ការអនុវត្តថវិកា និងកិច្ចការគ្រប់គ្រងសាច់ប្រាក់ ដើម្បីធានាបាននូវប្រសិទ្ធភាព ប្រសិទ្ធភាព និងនិរន្តរភាព។

គ. និយ័តករគណនេយ្យនិងសវនកម្ម គឺជាស្ថាប័នដែលទទួលបន្ទុកលើការកំណត់ស្តង់ដានៃអភិបាលកិច្ច និងការអភិវឌ្ឍវិស័យគណនេយ្យ និងសវនកម្ម និងវិជ្ជាជីវៈនៅកម្ពុជាតាមរយៈការណែនាំអំពីបទដ្ឋាន ច្បាប់ និងបទប្បញ្ញត្តិនានា។

ឃ. អាជ្ញាធរសវនកម្មជាតិ គឺជាស្ថាប័នសាធារណៈឯករាជ្យ និងរាយកាណ៍ដោយផ្ទាល់ជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលក្នុងគោលបំណងផ្តល់ព័ត៌មាន និងទទួលបន្ទុកក្នុងការធ្វើសវនកម្មហិរញ្ញវត្ថុលើស្ថាប័នសាធារណៈ។

ង. អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានភារកិច្ចអភិវឌ្ឍមុខងារនៅក្នុង FMIS ដើម្បីគាំទ្រដល់ការគ្រប់គ្រង តាមដាន ធ្វើកិច្ចបញ្ជិកាគណេនេយ្យនិងរាយការណ៍ពីសន្និធិ។

ច. អគ្គាធិការដ្ឋាន គឺជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលទទួលបន្ទុកក្នុងការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើអនុលោមភាពនិងសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងគ្រប់គ្រងហានិភ័យ តាមអនុសាសន៍របស់រាជរដ្ឋាភិបាល ដៃគូរអភិវឌ្ឍ និងស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ។

ឆ. អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង គឺជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលទទួលបន្ទុកពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ និងបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធភាព ប្រតិបត្តិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនាំមុខក្នុងការអភិវឌ្ឍមុខងារសវនកម្មផ្ទៃក្នុងនៅតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល។

**២.វិធីដំណើរការ**

កិច្ចប្រតិបត្តិការទាក់ទិននឹងការទទួលស្គាល់សន្និធិ ត្រូវឆ្លងកាត់ប្រតិបត្តិការចំណាយដែលត្រូវអនុវត្តតាម៥(ប្រាំ) ដំណាក់កាល រួមមាន៖(១)-ការធានាចំណាយ (២)-ការអនុវត្តកិច្ចលទ្ធកម្ម (៣)-ការជម្រះបញ្ជីចំណាយ (៤)-អាណាប័ណ្ណ និង (៥)-ការទូទាត់ ដូចមានចែងក្នុងមាត្រានៃអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

**៣. ឯកសារតម្រូវ**

ឯកសារតម្រូវសម្រាប់ការទទួលស្គាល់ចំណាយទិញសន្និធិ រួមមាន៖

- វិក្កយបត្រ
- អាណត្តិទូទាត់
- សក្ខីបត្រ

- លិខិតប្រគល់ ទទួល
- កិច្ចសន្យា ឬ កិច្ចព្រមព្រៀង
- ឯកសារផ្សេងទៀតតាមការចាំបាច់។

ឯកសារតម្រូវសម្រាប់ការទទួលស្គាល់ចំណូលពីការលក់សន្និធិ រួមមាន៖

- វិក្កយបត្រ
- សលាកបត្របង់ចំណូលថវិកា
- សក្ខីបត្រ
- បង្កាន់ដៃទទួលសាច់ប្រាក់ ឬ បង្កាន់ដៃបង់ប្រាក់ពីធនាគារ
- កិច្ចសន្យា ឬ កិច្ចព្រមព្រៀង
- ឯកសារផ្សេងទៀតតាមការចាំបាច់។

### ៤. សមតុល្យដើមគ្រានៃសន្និធិ

ក្នុងគណនីសៀវភៅធំ សន្និធិ គឺជាទ្រព្យសកម្មរយៈពេលខ្លី ដោយសារសន្និធិជាទំនិញដែលត្រូវលក់ ឬ ចែកចាយក្នុងកំឡុងពេល ១២ ខែ។ ជាទូទៅ សមតុល្យនៃសន្និធិ ត្រូវបានបង្ហាញជាធាតុមួយនៃទ្រព្យសកម្មរយៈពេលខ្លី នៃតារាងតុល្យការ។

ដើម្បីកត់ត្រាសន្និធិក្នុងឆ្នាំ គណនេយ្យករត្រូវកត់ត្រាខាងឥណពន្ធសន្និធិតាមវិក្កយបត្រ នៅពេលទទួលបានទំនិញ ការកត់ត្រាម្ខាងទៀតក្នុងប្រព័ន្ធទ្វេភាគ ត្រូវបដិភាគខាងឥណទាននៃគណនីសង សម្រាប់ទំនិញ ឬ សេវាកម្មដែលត្រូវបានទិញដោយឥណទាន ឬ រង់ចាំការទូទាត់សាច់ប្រាក់។

ឧទាហរណ៍៖ ស្ថាប័នសាធារណៈ (ក)ទិញស្រូវពូជសម្រាប់ផលិតលក់បន្តជូនអតិថិជន ក្នុងតម្លៃ៥ ០០០ ០០០ រៀល នៅពេលដែលស្ថាប័នសាធារណៈ (ក)ទទួលបានស្រូវពូជនិងវិក្កយបត្រ ត្រូវទទួលស្គាល់ជាសន្និធិ ដោយកត់ត្រាឥណពន្ធ ៥ ០០០ ០០០ រៀល នៅក្នុងគណនី ពូជនិងកូនរុក្ខជាតិ និងកត់ត្រាខាងឥណទាន ៥ ០០០ ០០០ រៀល ក្នុងគណនីសាច់ប្រាក់/គណនីធនាគារ ឬ ក្នុងគណនីត្រូវសង។

### ៥. ការរាប់សន្និធិជាក់ស្តែង

ជាវិធានការរដ្ឋបាលដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងសន្និធិ ស្ថាប័នសាធារណៈត្រូវធ្វើការរាប់សន្និធិដែលមានជាក់ស្តែងចំនួនមួយដង ក្នុងមួយឆ្នាំ។ ការរាប់សន្និធិជាក់ស្តែងត្រូវធ្វើឡើងដោយយកតួលេខសន្និធិរបស់គណនេយ្យករមករាប់ផ្ទៀងផ្ទាត់នឹងសន្និធិដែលមានជាក់ស្តែង តាមប្រភេទសន្និធិនីមួយៗដែលមាន។

### ៦. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់កត់ត្រា និងរាយការណ៍សន្និធិ

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងសន្និធិ គឺជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានមុខងារប្រមូលដំណើរការ រក្សាទុក និងរាយការណ៍ព័ត៌មានដែលទាក់ទិននឹងការគ្រប់គ្រងសន្និធិ។ ប្រព័ន្ធនេះ នឹងផ្តល់ទិន្នន័យដ៏មានសារសំខាន់ដែលអាចឱ្យអ្នកគ្រប់គ្រង ទទួលបានព័ត៌មានអំពីស្ថានភាពសន្និធិ ការរាយការណ៍ និងធ្វើការសម្រេចចិត្ត។ ទាំងប្រព័ន្ធ FMIS ឬ ប្រព័ន្ធ SARMIS គឺអាចមានលក្ខណៈសមស្របសម្រាប់ធ្វើការអភិវឌ្ឍមុខងារបន្ថែមក្នុងការគាំទ្រការធ្វើកិច្ចបញ្ជិកាគណនេយ្យពីសន្និធិនេះ។ ក្នុងករណីប្រើប្រព័ន្ធ SARMIS ក្នុងការគ្រប់គ្រងសន្និធិ ប្រព័ន្ធនេះត្រូវមានលទ្ធភាពក្នុងការធ្វើសន្ធានកម្មជាមួយប្រព័ន្ធ FMIS ដើម្បីអាចធ្វើកិច្ចបញ្ជិកាគណនេយ្យ បង្កើតរបាយការណ៍ស្តីពីសន្និធិ។

### ៧. ការរាយការណ៍សន្និធិ

ស្ថាប័នសាធារណៈ ត្រូវរៀបចំរបាយការណ៍ស្តីពីស្ថានភាពរួមនៃសន្និធិដែលមានទម្រង់ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃគោលការណ៍ណែនាំនេះ។

### ៨. ការដាក់បង្ហាញសន្និធិក្នុងរបាយការណ៍

របាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នសាធារណៈត្រូវបង្ហាញព័ត៌មានអំពីសន្និធិដូចមានខាងក្រោម៖

(ក) គោលការណ៍គណនេយ្យដែលបានប្រើប្រាស់ក្នុងការវាស់វែងតម្លៃសន្និធិ រួមទាំងរូបមន្តគិតថ្លៃដើមសន្និធិដែលបានប្រើ

(ខ) តម្លៃយោងសរុបនៃសន្និធិ និងតម្លៃយោងនៅក្នុងចំណាត់ថ្នាក់ដែលសមស្រប

(គ) តម្លៃយោងសន្និធិគិតតាមតម្លៃសមស្របដកចំណាយក្នុងការលក់

(ឃ) សន្និធិដែលត្រូវបានទទួលស្គាល់ជាការចំណាយក្នុងអំឡុងពេល

(ង) ការបន្ថយតម្លៃសន្និធិដែលត្រូវបានទទួលស្គាល់ថាជាការចំណាយក្នុងការិយបរិច្ឆេទ

(ច) ការធ្វើប្រតិក្រាន្តនៃសំវិធានធនសន្និធិក្នុងការិយបរិច្ឆេទដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលហិរញ្ញវត្ថុ

(ឆ) មូលហេតុ ឬ ព្រឹត្តិការណ៍ដែលនាំឱ្យមានការធ្វើប្រតិក្រាន្តនៃសំវិធានធនសន្និធិក្នុងការិយបរិច្ឆេទ

(ជ) តម្លៃយោងនៃសន្និធិដែលបានដាក់ជានាបំណុល។

**ឧបសម្ព័ន្ធ១៖ ការផ្គូផ្គងសន្និធិជាមួយនឹងលក្ខខណ្ឌតម្រូវនៃស្តង់ដាគណនេយ្យសាធារណៈកម្ពុជា**

| ប្រភេទសន្និធិ<br>តាមលិខិតបទដ្ឋានគតិយុត្តជាធរមាន | មាតិកា<br>គណនី | ស្តង់ដាគណនេយ្យសាធារណៈ<br>កម្ពុជានិងអន្តរជាតិ | លក្ខខណ្ឌនិងពេលវេលានៃការទទួលស្គាល់ |
|---|---|---|---|
| **សន្និធិ** | **17** | - ស្តង់ដាលេខ១២ ស្តីពីសន្និធិ | **១. លក្ខខណ្ឌនៃការទទួលស្គាល់សន្និធិ**<br>- ចំណុច ២. ផ្នែក១ នៃជំពូកទី២។<br>**២. ពេលវេលានៃការទទួលស្គាល់**<br>ក. មានសិទ្ធិគ្រប់គ្រង និងចាត់ចែងលើសន្និធិ<br>ខ. ស្ថាប័នសាធារណៈទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាកម្មដែលអាចកើតឡើងពីសន្និធិ<br>គ. ថ្លៃដើមនៃសន្និធិអាចវាស់វែងបានប្រកបដោយភាពជឿជាក់។ |
| **១. សន្និធិសម្ភារផ្គត់ផ្គង់ថែទាំ** | **1701** | | |
| សម្ភារផ្គត់ផ្គង់សម្អាតនិងអនាម័យ | 17011 | | |
| សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ | 17012 | | |
| សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំផ្លូវថ្នល់ ស្ពាន និងលូ | 17013 | | |
| សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារ ឧបករណ៍ | 17014 | | |
| ប្រេងឥន្ធនៈនិងប្រេងរំអិល | 17015 | | |
| សម្ភារផ្គត់ផ្គង់ថែទាំផ្សេងៗ | 17018 | | |
| **២. សន្និធិសម្ភារផ្គត់ផ្គង់រដ្ឋបាល** | **1702** | | |
| សម្ភារការិយាល័យនិងការបោះពុម្ព | 17021 | | |
| សៀវភៅមើលនិងឯកសារ | 17022 | | |
| សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ | 17028 | | |
| **៣. សន្និធិស្បៀងអាហារ និងផលិតផលកសិកម្ម** | **1703** | | |
| ស្បៀង | 17031 | | |
| ចំណីសត្វ | 17032 | | |
| ពូជនិងកូនរុក្ខជាតិ | 17033 | | |
| ផលិតផលការពារសុខុមាលភាពរុក្ខជាតិនិងជី | 17034 | | |

| | | | |
|---|---|---|---|
| ពូជសត្វ ឱសថ និងវត្ថុធាតុសម្រាប់បសុពេទ្យ | 17035 | | |
| ស្បៀងអាហារ និងផលិតផលកសិកម្មផ្សេងៗ | 17038 | | |
| **៤. សន្និធិសំលៀកបំពាក់និងការតុបតែង** | **1704** | | |
| ឯកសណ្ឋាន | 17041 | | |
| សំលៀកបំពាក់ការពារសុវត្ថិភាព | 17042 | | |
| មេដាយ (គ្រឿងឥស្សរិយយស) | 17043 | | |
| សំលៀកបំពាក់និងការតុបតែងផ្សេងៗ | 17048 | | |
| **៥. សន្និធិសម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារ** | **1705** | | |
| សម្ភារនិងបរិក្ខារបច្ចេកទេស | 17051 | | |
| សង្ហារឹម | 17052 | | |
| សម្ភារប្រើប្រាស់ | 17053 | | |
| សម្ភារនិងឧបករណ៍ដឹកជញ្ជូន | 17054 | | |
| សម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារផ្សេងៗ | 17058 | | |
| **៦. សន្និធិសម្ភារបរិក្ខារថែទាំសុខភាព** | **1707** | | |
| បំពង់ហ្គាសនិងអុកស៊ីសែន | 17071 | | |
| សម្ភារបរិក្ខារពេទ្យ | 17072 | | |
| សម្ភារបរិក្ខារថែទាំសុខភាពផ្សេងៗ | 17078 | | |
| **៧. សន្និធិសម្ភារផ្គត់ផ្គង់ផ្សេងៗ** | **1708** | | |
| **ចំណាយថ្លៃដើមសន្និធិ** | | | |
| សម្ភារផ្គត់ផ្គង់ថែទាំ | 6001 | | |
| សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល | 6002 | | |
| ស្បៀងអាហារ និងផលិតផលកសិកម្ម | 6003 | | |

| | | | |
|---|---|---|---|
| ស្បៀង | 60031 | | |
| ចំណីសត្វ | 60032 | | |
| ពូជ និងកូនរុក្ខជាតិ | 60033 | | |
| ផលិតផលការពារសុខុមាលភាពរុក្ខជាតិ និងជី | 60034 | | |
| ពូជសត្វ | 60035 | | |
| ឱសថ និងវត្ថុធាតុសម្រាប់បសុពេទ្យ | 60036 | | |
| ស្បៀងសម្រាប់រដ្ឋបាល | 60037 | | |
| ស្បៀងអាហារ និងផលិតផលកសិកម្មផ្សេងៗ | 60038 | | |
| **សំលៀកបំពាក់ និងការតុបតែង** | **6004** | | |
| **សម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារ** | **6005** | - ស្តង់ដាលេខ១២ ស្តីពីសន្និធិ | **១. លក្ខខណ្ឌនៃការទទួលស្គាល់**<br>- ចំណុច ២. ផ្នែក២ នៃជំពូកទី២។<br>**២. ពេលវេលានៃការទទួលស្គាល់**<br>ស្ថាប័នសាធារណៈត្រូវកត់ត្រាទទួលស្គាល់ សន្និធិជាចំណាយថ្លៃដើម នៅពេលដែលសន្និធិត្រូវបានលក់ ឬ ចែកចាយ។ |
| **ថាមពលនិងទឹក** | **6006** | | |
| អគ្គិសនី | 60061 | | |
| ទឹក | 60062 | | |
| ផ្សេងៗ | 60068 | | |
| **សម្ភារបរិក្ខារថែទាំសុខភាព** | **6007** | | |
| បំពង់ហ្គាសនិងអុកស៊ីសែន | 60071 | | |
| សម្ភារបរិក្ខារពេទ្យ | 60072 | | |
| សម្ភារបរិក្ខារថែទាំសុខភាពផ្សេងៗ | 60078 | | |
| **សម្ភារផ្គត់ផ្គង់ផ្សេងៗ** | **6098** | | |
| សម្ភារផ្គត់ផ្គង់ផ្សេងៗ | 60981 | | |

## ឧបសម្ព័ន្ធ២៖ គំរូរបាយការណ៍សន្និធិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

{Logo}
**ឈ្មោះស្ថាប័នសាធារណៈ**
លេខ.................................

ថ្ងៃ..........ខែ..........ឆ្នាំ.........ស័ក ព.ស.............
ធ្វើនៅ..............ថ្ងៃទី............ខែ......ឆ្នាំ.............

**របាយការណ៍ស្ដីពីស្ថានភាពសន្និធិ**
**របស់(ឈ្មោះស្ថាប័នសាធារណៈ)**

ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០XX

ឯកតា÷រៀល

| ល.រ. | ប្រភេទសន្និធិ | សមតុល្យដើមគ្រា | | សន្និធិដែលបានកើតឡើងក្នុងឆ្នាំ | | សន្និធិដែលបានទូទាត់ក្នុងឆ្នាំ | | សន្និធិដែលបានលុបចេញក្នុងឆ្នាំ | | ការកែតម្រូវ | | សមតុល្យចុងគ្រា | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | 1 | | 2 | | 3 | | 4 | | 5 | | 6=1+2-3-4(-/+)5 | |
| | | ឯកតា | តម្លៃ | ឯកតា | តម្លៃ | ឯកតា | តម្លៃ | ឯកតា | តម្លៃ | ឯកតា | តម្លៃ | ឯកតា | តម្លៃ |
| ១ | សន្និធិសម្ភារផ្គត់ផ្គង់ថែទាំ | | | | | | | | | | | | |
| ២ | សន្និធិសម្ភារផ្គត់ផ្គង់រដ្ឋបាល | | | | | | | | | | | | |
| ៣ | សន្និធិស្បៀងអាហារ និងផលិតផលកសិកម្ម | | | | | | | | | | | | |
| ៤ | សន្និធិសម្ភារបរិក្ខារថែទាំសុខភាព | | | | | | | | | | | | |
| ៥ | សន្និធិសម្ភារផ្គត់ផ្គង់ផ្សេងៗ | | | | | | | | | | | | |
| | **សរុបរួម** | | | | | | | | | | | | |

**កំណត់សម្គាល់÷** សូមពន្យល់អំពីមូលហេតុ ឬព្រឹត្តិការណ៍នានាដែលនាំឱ្យមានការប្រែប្រួលតួលេខសន្និធិ។

ប្រធានស្ថាប័នសាធារណៈ ប្រធានផ្នែកហិរញ្ញវត្ថុ អ្នកទទួលបន្ទុកផ្នែកគ្រប់គ្រងសន្និធិ

ឧបសម្ព័ន្ធ៣៖ គំរូរបាយការណ៍រួមសន្និធិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

{Logo}
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានរតនាគារជាតិ**
លេខ................................

**របាយការណ៍សរុបរួមស្តីពីស្ថានភាពសន្និធិ**
**របស់រាជរដ្ឋាភិបាលកម្ពុជា**
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០XX

ឯកតា៖រៀល

| ល.រ. | ប្រភេទសន្និធិ | កំណត់សម្គាល់ | ឆ្នាំសារពើពន្ធ N | | ឆ្នាំសារពើពន្ធ N-1 | |
|---|---|---|---|---|---|---|
| | | | ឯកតា | តម្លៃ | ឯកតា | តម្លៃ |
| ១ | សន្និធិសម្ភារផ្គត់ផ្គង់ថែទាំ | (...) | | | | |
| ២ | សន្និធិសម្ភារផ្គត់ផ្គង់រដ្ឋបាល | (...) | | | | |
| ៣ | សន្និធិស្បៀងអាហារ និងផលិតផលកសិកម្ម | | | | | |
| ៤ | សន្និធិសម្ភារបរិក្ខារថែទាំសុខភាព | | | | | |
| ៥ | សន្និធិសម្ភារផ្គត់ផ្គង់ផ្សេងៗ | | | | | |
| | សរុបសន្និធិ | | | | | |

**កំណត់សម្គាល់៖**
នាយកដ្ឋានគណនេយ្យ ត្រូវពន្យល់អំពីមូលហេតុ ឬព្រឹត្តិការណ៍នានាដែលនាំឱ្យមានការប្រែប្រួលតួលេខសន្និធិក្នុងឆ្នាំ។

ថ្ងៃ..........ខែ..........ឆ្នាំ.........ស័ក ព.ស.............
ធ្វើនៅ..............ថ្ងៃទី...........ខែ......ឆ្នាំ.............
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ

ប្រធាន
នាយកដ្ឋានគណនេយ្យ

ប្រធាន
ការិយាល័យគណនេយ្យទី១ និងសរុប

ថ្ងៃ..........ខែ..........ឆ្នាំ.........ស័ក ព.ស.............
ធ្វើនៅ..............ថ្ងៃទី...........ខែ......ឆ្នាំ.............
អ្នករៀបចំ

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានរតនាគារជាតិ**

អគារលេខ១៩ វិថីព្រះមហាក្សត្រីយានីកុសមៈ
(ផ្លូវលេខ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
អ៊ីម៉ែល៖ info@treasury.gov.kh
វេបសាយ៖ www.treasury.gov.kh